រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

002KH01A-01

អត្ថបទសិក្សា ទី ១

"ដំណឹងល្អបំផុត"



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

គ្រោះថ្នាក់ខាងព្រលឹងវិញ្ញាណ ដែលយើងអាចជួបប្រទះ

នេះជាដំណើររឿងអំពីក្រុមគ្រួសារលោកណូអេ ។ លោកណូអេជាមនុស្សសុចរិតទៀងត្រង់ នៅក្នុងចំណោមអស់អ្នកដែលរស់នៅជំនាន់លោក ។ លោកបានដើរតាមមាគ៌ារបស់ព្រះជាម្ចាស់ ។

ព្រះជាម្ចាស់ទតឃើញថា ផែនដីអាក្រក់ខ្លួចអស់ ដ្បិតមនុស្សលោកទាំងប៉ុន្មាននៅលើផែនដី សុទ្ធតែមានកិរិយាមារយាទខិលខ្លួចអាក្រក់ ។ ព្រះជាម្ចាស់ក៏មានព្រះបន្ទូលមកកាន់លោកណូអេថា÷ *«យើងបានសំរេចចិត្តផ្តាច់ជីវិតសត្វលោកទាំងអស់ ដ្បិតមនុស្សបានធ្វើឱ្យផែនដីពោរពេញដោយអំពើឃោរឃៅ ។ ដូច្នេះយើងនឹងលុបបំបាត់គេអោយវិនាសសូន្យទៅជាមួយផែនដី »* ។

ព្រះជាម្ចាស់មានព្រះបន្ទូលទៅលោកណូអេថា÷ *«ចូរអ្នកយកស្រឡៅមកធ្វើទូកមួយយ៉ាងធំ ហើយចែកទូកធំនេះជាច្រើនបន្ទប់ ព្រមទាំងយកជ័រមកលាបភ្លឺតទាំងក្នុង ទាំងក្រៅផង...។ រីឯយើងវិញ យើងនឹងធ្វើអោយទឹកជន់លិចផែនដី ដើម្បីបំផ្លាញសត្វលោកទាំងអស់ ដែលមានជង្ហើមជីវិតនៅក្រោមមេឃ ។ អ្វីៗទាំងអស់នៅលើផែនដីនឹងត្រូវវិនាសសូន្យ ប៉ុន្តែ យើងនឹងចងសម្ពន្ធមេត្រីជាមួយអ្នក »* ។

តើព្រះយេស៊ូនៅសុគតរហូតឬ ?

_____

តើមានការអ្វីកើតឡើងនៅថ្ងៃទីបី ?

_____

_____

ខ សំរាប់ទន្ទេញ

«ប៉ុន្តែ បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត ទ្រង់នឹងអត់ទោសយើងអោយរួចពីបាប ព្រមទាំងជំរះយើងឱ្យបានបរិសុទ្ធរួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង »។ (១ យ៉ូហាន ១:៩)

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានលន់តួសារភាពអំពើបាបរបស់អ្នកទៅព្រះជាម្ចាស់។
- និទានរឿងទឹកជំនន់ប្រាប់គ្រួសារអ្នក ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

© Project WorldReach © SEAN

យោងទៅតាមព្រះបន្ទូលព្រះជាម្ចាស់ សេចក្តីទាំងនេះជាលទ្ធផលនៃអំពើបាប ។

រឿងពីសម័យបុរាណអំពីទូក ដែលបានសង្គ្រោះមនុស្សប្រាំបីនាក់អោយរួចពីទឹកជំនន់ ធ្វើអោយយើងនឹកឃើញពីព្រឹត្តិការណ៍មួយទៀត ដែលមានសារៈសំខាន់ខ្លាំងជាង សំរាប់ពេលសព្វថ្ងៃនេះ ។ ព្រះគម្ពីរចែងថា ព្រះយេស៊ូគ្រីស្តបានសុគត ដើម្បីធ្វើជាយញ្ញបូជាលោះបាបរបស់យើង ។ ព្រះអង្គជា «ទូក» ដែលសង្គ្រោះយើងពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់ ។ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី ។

តើយើងនឹងមានគ្រោះថ្នាក់ដូចម្តេច បើសិនជាយើងមិនបានព្រះ-ជាម្ចាស់លើកលែងទោសអំពើបាប ដោយសារព្រះយេស៊ូគ្រីស្តទេ?

«អ្នកនឹងចូលទៅក្នុងទូកធំជាមួយកូនប្រុសទាំងបី ប្រពន្ធ និងកូនប្រសារស្រីរបស់អ្នក ។ អ្នកក៏ត្រូវនាំយកសត្វមួយគូៗពីបណ្តាសត្វទាំងអស់ចូលទៅក្នុងទូកធំ ដើម្បីអោយវាបានរួចជីវិត រួមជាមួយអ្នកដែរ គឺត្រូវយកឈ្មោលមួយ ញីមួយ ។ សត្វមួយគូៗក្នុងពូជនីមួយៗនឹងនាំគ្នាមករកអ្នក ដើម្បីអោយបានរួចជីវិត គឺមានសត្វស្លាប សត្វស្រុក សត្វលូនវារនៅលើដី ។ អ្នកក៏ត្រូវយកគ្រឿងបរិភោគទាំងប៉ុន្មាន ទុកជាស្បៀងអាហារសំរាប់បរិភោគ និងទុកជាចំណីសំរាប់សត្វដែរ » ។

លោកណូអេក៏ធ្វើដូច្នោះមែន គឺលោកធ្វើសព្វគ្រប់ទាំងអស់ដូចព្រះជាម្ចាស់បានបង្គាប់ ។ ព្រះអម្ចាស់មានបន្ទូលមកកាន់លោកណូអេថា÷ *«ចូរអ្នកចូលទៅក្នុងទូកធំជាមួយក្រុមគ្រួសារទាំងមូលរបស់អ្នកទៅ ដ្បិតយើងបានឃើញថា ក្នុងចំណោមមនុស្សជំនាន់នេះមានតែអ្នកទេ ដែលសុចរិត....។ ដ្បិតប្រាំពីរថ្ងៃទៀត យើងនឹងធ្វើអោយភ្លៀងបង្អុរចុះមកលើផែនដី ក្នុងរយៈពេលសែសិបថ្ងៃសែសិបយប់ ហើយយើងនឹងលុបបំបាត់សត្វលោកទាំងប៉ុន្មានដែលយើងបានបង្កើតមកអោយអស់ពីផែនដី »* ។

© Project WorldReach © SEAN

លោកណូអេបានធ្វើតាមសព្វគ្រប់ទាំងអស់ ដូចព្រះអម្ចាស់បង្គាប់។ ប្រាំពីរថ្ងៃក្រោយមក ទឹកជំនន់ធំក៏ជន់ឡើងលិចផែនដី ។ សត្វមានជីវិតទាំងប៉ុន្មាន នាំគ្នាទាំងគូៗ មករកលោកណូអេនៅក្នុងទូកធំ គឺមានសត្វទាំងឈ្មោល ទាំងញីពីគ្រប់ពូជ ចូលមកក្នុងទូកធំ ដូចព្រះជាម្ចាស់បានបង្គាប់មកលោកណូអេរួចហើយ ព្រះអម្ចាស់ក៏បិទទ្វារទូកនោះទៅ ។

ទឹកជំនន់ធំបានលិចផែនដីអស់ពេលរយៈពេលសែសិបថ្ងៃ ។ ទឹកបានជន់ឡើង ហើយលើកទូកធំអោយអណ្តែតឡើងផុតពីដី ។ ទឹកជន់កាន់តែខ្លាំងឡើងៗ កំពស់ទឹកកើនឡើងយ៉ាងខ្ពស់ ហើយទូកធំនៅអណ្តែតពីលើផ្ទៃទឹក ។ ទឹកជន់លិចភ្នំទាំងឡាយ ហើយឡើងហួសភ្នំទាំងនោះដប់ប្រាំហត្ថ ។

សត្វលោកទាំងឡាយដែលរស់នៅលើផែនដី ក៏វិនាសសូន្យអស់ទៅ គឺទាំងបក្សាបក្សី សត្វស្រុកសត្វព្រៃ និងសត្វទាំងប៉ុន្មាន ដែលនៅរវើករវាំណ្ឌ ពាសពេញលើផែនដី និងមនុស្សលោកទាំងអស់ដែរ។ អ្វីៗទាំងអស់ដែលមានជង្ហើមជីវិត និងរស់នៅលើដីគោក ក៏ស្លាប់អស់ទៅ...។ នៅសល់តែលោកណូអេ និងអស់អ្នកដែលស្ថិតនៅក្នុងទូកធំជាមួយលោកប៉ុណ្ណោះ ។ (កំណើតពិភពលោក ៦:៩ ដល់ ៧:២៤) ។

ឥឡូវនេះ សូមសរសេរចំលើយរបស់អ្នកចំពោះសំនួរទាំងនេះ :

ហេតុអ្វីបានជាព្រះជាម្ចាស់សង្គ្រោះលោកណូអេ ?

ហេតុអ្វីបានជាព្រះជាម្ចាស់ដាក់ទោសពិភពលោក កាលពីសម័យដើមយូរលង់នោះ ?

សព្វថ្ងៃនេះ ក៏ព្រះជាម្ចាស់ទតមើលមកផែនដីដែរ ។ តើអ្នកគិតថាព្រះអង្គគិតយ៉ាងណាអំពីពិភពលោកសព្វថ្ងៃនេះ ? តើព្រះអង្គសប្បាយព្រះទ័យ ឬនឹកស្តាយពិភពលោកសព្វថ្ងៃនេះ ?

សូមគូសបន្ទាត់ពីក្រោមសេចក្តីដែលជាលទ្ធផលនៃអំពើបាប :

សង្គ្រាម	**ឧក្រិដ្ឋកម្ម**	**ការបែកបាក់គ្រួសារ**
ទុក្ខព្រួយ	**ភាពក្រខ្សត់**	**ការជំនុំជំរះអស់លក្ស**
ការភ្ញាក់ផ្អើល	**សេចក្តីស្លាប់**	